ការបកប្រែទិន្នន័យគម្រោង (PDS) នេះ គឺផ្អែកលើភាសាអង់គ្លេស ចុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

# ADB ធនាគារអភិវឌ្ឍន៍អាស៊ី

## កម្ពុជា ៖ គម្រោងអភិវឌ្ឍខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្មដែលមិនបង្កផលប៉ះពាល់ដល់អាកាសធាតុ

| | |
|---|---|
| **ឈ្មោះគម្រោង** | **គម្រោងអភិវឌ្ឍខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្មដែលមិនបង្កផលប៉ះពាល់ដល់អាកាសធាតុ** |
| លេខគម្រោង | 48409-002 |
| ប្រទេស | កម្ពុជា |
| **ស្ថានភាពគម្រោង** | បានស្នើសុំ |
| **ប្រភេទគម្រោង/គំរូនៃការផ្តល់ជំនួយ** | **កម្ចី** |
| ប្រភពមូលនិធិ/ចំនួន | ជំនួយឥតសំណង ៖ **ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្មដែលមិនបង្កផលប៉ះពាល់ដល់អាកាសធាតុ** |
| | ហេដ្ឋារចនាសម្ព័ន្ធបរិស្ថានសកល (Global Environment Facility) — ៥លានដុល្លារសហរដ្ឋអាមេរិក |
| | មូលនិធិអភិវឌ្ឍន៍ ន័រឌិក (Nordic Development Fund) — ៥លានដុល្លារសហរដ្ឋអាមេរិក |
| | កម្ចី ៖ **ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃកសិធុរកិច្ចដែលមិនបង្កផលប៉ះពាល់ដល់អាកាសធាតុ** |
| | **មូលនិធិអភិវឌ្ឍន៍អាស៊ី** — ៥០លានដុល្លារសហរដ្ឋអាមេរិក |
| **របៀបវារៈយុទ្ធសាស្ត្រ** | កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពផ្នែកបរិស្ថាន<br>កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា<br>សមាហរណកម្មតំបន់ |

| | |
|---|---|
| **កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ** | អភិបាលកិច្ច និងការអភិវឌ្ឍន៍សមត្ថភាព<br>ដំណោះស្រាយផ្នែកចំណេះដឹង<br>ភាពជាដៃគូ<br>ការអភិវឌ្ឍន៍វិស័យឯកជន |
| **វិស័យ/អនុវិស័យ** | កសិកម្ម, ធនធានធម្មជាតិ និងអភិវឌ្ឍន៍ជនបទ -<br>គោលនយោបាយកសិកម្ម ការអភិវឌ្ឍន៍ស្ថាប័ន និងការអភិវឌ្ឍន៍សមត្ថភាព -<br>ផលិតកម្មកសិកម្ម - កសិឧស្សាហកម្ម ការធ្វើទីផ្សារ និង ការធ្វើពាណិជ្ជកម្ម -<br>ការអភិវឌ្ឍន៍ដីធ្លីដោយផ្អែកលើការគ្រប់គ្រងធនធានធម្មជាតិ |
| **សមធម៌យេនឌ័រ និង ការបញ្រ្ជាបយេនឌ័រ** | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |
| **ការពណ៌នា** | ការសិក្សានាពេលថ្មីៗនេះ បានបង្ហាញឱ្យដឹងថា ការវិនិយោគទៅលើវិស័យកសិ-កម្ម គឺជាយុទ្ធសាស្រ្តមួយក្នុងចំណោមយុទ្ធសាស្រ្តនានា ដែលមានប្រសិទ្ធភាពខ្ពស់ និងចំណាយតិចបំផុត ដើម្បីកាត់បន្ថយភាពក្រីក្រ និង ភាពអត់ឃ្លាន។ គម្រោងវិស័យខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្មមិនបង្កផលប៉ះពាល់ដល់អាកាសធាតុ ដែលបានស្នើឡើង (ហៅកាត់ថា គម្រោង) នឹងធ្វើការវិនិយោគទៅលើខ្សែសង្វាក់តម្លៃកសិកម្មសម្រាប់ទាំងអស់គ្នា ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា។ គម្រោងនេះ នឹងលើកកម្ពស់ប្រាក់ចំណូលរបស់គ្រួសារជនបទ និងការប្រកួតប្រជែងវិស័យកសិកម្ម តាមរយៈ (១) ការផ្តល់នូវផលិតកម្មសំខាន់ៗដែលមានភាពប្រសើរជាងមុន និងហេដ្ឋារចនាសម្ព័ន្ធក្រោយពេលប្រមូលផល (២) ការកាត់បន្ថយថ្លៃចំណាយ ថាមពល តាមរយៈការលើកកម្ពស់ការប្រើប្រាស់ជីវថាមពល និងការ គ្រប់គ្រងជីវម៉ាស់ប្រកបដោយនិរន្តរភាព និង (៣) ការផ្តល់គោលនយោបាយ កសិពាណិជកម្ម និងសេវាគាំទ្រសមត្ថភាពដោយមានគោលដៅ។ ការផ្តល់កម្ចីតាមវិស័យ ត្រូវបានលើកជាសំណើឡើង អាស្រ័យដោយវានឹងបង្កលក្ខណៈជួយធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយកសិពាណិ-ជកម្ម និងគាំទ្រដល់កំណែទម្រង់ ស្របពេលជាមួយគ្នាទៅនឹងការផ្តល់ហិរញ្ញ-ប្បទានដល់ការវិនិយោគទៅលើអនុគម្រោងជាច្រើន។ ប្រទេសកម្ពុជាមានបទពិសោធន៍នៅក្នុងគំរូវិស័យទាក់ទងទៅនឹងការកំណត់ និងការអនុវត្តន៍អនុគម្រោងនានា នៅក្នុងរយៈពេលអនុវត្តគម្រោង និងមានលក្ខខណ្ឌស្របទៅនឹងលក្ខណៈវិនិច្ឆ័យ សម្រាប់ការផ្តល់កម្ចីតាមវិស័យ អាស្រ័យដោយប្រទេសនេះមាន (១) ផែនការអភិវឌ្ឍន៍វិស័យកសិកម្ម (២) សមត្ថភាពស្ថាប័នសមស្របសម្រាប់អនុវត្តផែនការ និង (៣) គោលនយោបាយសមស្របដែលអាចយកមកអនុវត្តបាន |

សម្រាប់វិស័យនេះ។ បន្ថែមពីនេះទៀត ការកសាងសមត្ថភាព នឹងក្លាយជាធាតុស្នូលនៃការវិនិយោគ។ ផលប៉ះពាល់ នឹងរួមមានកំណើនផលិតភាពគុណភាព ការបន្ថែមតម្លៃ និង ប្រាក់ចំណូលគ្រួសារជនបទនៅក្នុងតំបន់អនុវត្តគម្រោង។ លទ្ធផល នឹងរួមមានការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្ម ដែលមិនប៉ះពាល់ដល់បរិស្ថាន។ គម្រោងនេះ នឹងមានធាតុចេញចំនួន៣។ ធាតុចេញទី១ (ហេដ្ឋារចនាសម្ព័ន្ធខ្សែសង្វាក់តម្លៃកសិធុរកិច្ចសំខាន់ៗ ត្រូវបានកែលម្អ) នឹងរួមមានការស្តារ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ (ឧ. ផ្លូវតាមវាលស្រែ អាងស្តុកទឹក និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់សម្ងួត រក្សាទុក កិនស្រូវ និងវេចខ្ចប់ ដែលធ្វើឡើងដោយវិស័យសាធារណៈ និងវិស័យឯកជន។ សកម្មភាពទាំងនេះ នឹងកាត់បន្ថយការ ខាតបង់ក្រោយពេលប្រមូលផល និងកែលម្អប្រសិទ្ធផល។ ធាតុចេញទី២ (ការប្រើប្រាស់ជីវថាមពល និងការគ្រប់គ្រងជីវម៉ាស់ប្រកបដោយនិរន្តរភាព ត្រូវបានពង្រីក) នឹងរួមមានការតម្លើងហេដ្ឋា-រចនាសម្ព័ន្ធសម្រាប់បម្លែង កាកសំណល់កសិកម្មទៅជាថាមពល (រឹង និង ទន់) ដូចជា ឡជីវឧស្ម័ន ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិតជីពីឡជីវឧស្ម័ន និងចង្ក្រានដាំស្ល ដែលមាន លក្ខណៈប្រសើរជាងមុន ដើម្បីគ្រប់គ្រងជីវម៉ាស់ប្រកបដោយប្រសិទ្ធភាព។ សកម្មភាពទាំងនេះ នឹងបង្កើនការប្រកួតប្រជែងតម្លៃតាមរយៈការធ្វើឱ្យថ្លៃ ចំណាយផលិតកម្មមានការធ្លាក់ចុះ។ ធាតុចេញទី៣ (គោលន-យោបាយ កសិធុរកិច្ច និង សេវាគាំទ្រសមត្ថភាព ត្រូវបានពង្រឹង) នឹងរួមមានការអភិវឌ្ឍន៍គោលនយោបាយ/និយ័តកម្មស្តីពីកសិធុរកិច្ច ការកំណត់រក កាលា-នុវត្តភាពសម្រាប់តភ្ជាប់ទំនាក់ទំនងក្រុមហ៊ុនវិស័យឯកជនជាមួយកសិករ ឬ ក្រុមកសិករ ការផ្តល់ព័ត៌មានអំពីកសិកម្មដែលមិនប៉ះពាល់ដល់ អាកាសធាតុ និងការអនុវត្តន៍ដែលចំណាយធនធានតិច ប៉ុន្តែមាន ប្រសិទ្ធភាពខ្ពស់ ការធ្វើសុខដុម-នីយកម្មទៅលើបទដ្ឋាននានា និងការកសាង សមត្ថភាព សម្រាប់ផលិតភាព និងការកែលម្អគុណភាព ព្រមទាំងការកាត់បន្ថយការខាតបង់ក្រោយពេលប្រមូលផល ការធ្វើទីផ្សារ ភាពជាដៃគូ រវាងវិស័យសាធារណៈ និងវិស័យឯកជន (PPPs) ប្រកបដោយសក្តានុពល និងជម្រើសនៃការផ្តល់ហិរញ្ញប្បទាន។ វាក៏នឹងរួមមានផងដែរនូវកិច្ចគាំទ្ររបស់ទីប្រឹក្សា និង ការពង្រឹងស្ថាប័នសម្រាប់ការរៀបចំអនុ-គម្រោង ការធ្វើលទ្ធកម្ម ការគ្រប់គ្រង និងកិច្ចការពារហិរញ្ញវត្ថុ ព្រមទាំងការផ្សព្វផ្សាយ ចំណេះដឹង និងបច្ចេកវិទ្យាសម្រាប់ខ្សែសង្វាក់តម្លៃកសិធុរកិច្ច។

| | |
|---|---|
| **សនិទានភាពគម្រោង និងការតភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រទេស/តំបន់** | ប្រទេសកម្ពុជា ផ្គត់ផ្គង់ទំនិញកសិកម្មសំខាន់ៗមួយចំនួនសម្រាប់មហាអនុតំបន់ទន្លេមេគង្គ និង បណ្ដាប្រទេសដទៃទៀត។ ដៃគូអភិវឌ្ឍន៍ជាច្រើនរាប់បញ្ចូលទាំងធនាគារអភិវឌ្ឍន៍អាស៊ី បានគាំទ្រដល់ការផ្តួចផ្តើមនានាដើម្បីកែលម្អផលិតភាពកសិកម្ម។ បើទោះជាដូច្នេះក្តី វិស័យកសិកម្មរបស់កម្ពុជា មិនទាន់មានលក្ខណៈប្រកួតប្រជែងនៅឡើយ បើពិនិត្យមើលទៅលើទិដ្ឋភាពជាច្រើនរបស់វិស័យនេះ។ ទីមួយ ខ្សែសង្វាក់តម្លៃកសិកម្មរបស់វិស័យនេះ ពុំមានការអភិវឌ្ឍន៍ល្អ បើធៀបទៅនឹងប្រទេសជិតខាង ហើយទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ក៏ដូច្នោះដែរ។ ទីពីរ វិស័យនេះជារួមទទួលរងផលប៉ះពាល់ពីកង្វះខាតហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។ ទីបី ថ្លៃចំណាយសម្រាប់ផលិតកម្ម និង ការចែកចាយមានកម្រិតខ្ពស់ ភាគច្រើនគឺដោយសារតែថ្លៃចំណាយលើថាមពល និងការដឹកជញ្ជូនមានកម្រិតខ្ពស់ ហើយការខាតបង់ក្រោយពេលប្រមូលផល ក៏មានកម្រិតខ្ពស់ផងដែរ ចំពោះទម្ងន់ និងគុណភាពរបស់ផលិតផល។ បើទោះបីជាប្រជាពលរដ្ឋជាង ៦០% គឺជាកសិករ ដែលក្នុងនោះមានស្ត្រីប្រមាណ ៧០% ក៏ដោយ ប៉ុន្តែការវិនិយោគលើវិស័យកសិកម្មក្នុងប្រទេសកម្ពុជា មិនទាន់បានផ្តល់ជាប្រយោជន៍គួរឱ្យកត់សម្គាល់ ជូនដល់ប្រជាពលរដ្ឋទាំងនេះឡើយ។ ការវិនិយោគរបស់វិស័យឯកជន នៅតែបន្តមានកម្រិតទាប ដោយសារតែបរិយាកាសធុរកិច្ចមិនអំណោយផល។ សេរីភាវូនីយកម្មទីផ្សារ និងវិធានស្តីពីការធ្វើពាណិជ្ជកម្មសកលកំពុងមានការផ្លាស់ប្តូរ ដែលទាមទារឱ្យមានគុណភាព និងស្តង់ដារសុវត្ថិភាពចំណីអាហាររឹងមាំ កំពុងរាំងស្ទះដល់កសិករខ្នាតតូចក្នុងការចូលទៅក្នុងទីផ្សារប្រកួតប្រជែង។ បើទោះបីជាមានតម្រូវការទីផ្សារខ្លាំងក្លាក៏ដោយ ប៉ុន្តែខ្សែសង្វាក់កសិពាណិជ្ជកម្ម នៅតែបន្តមានភាពបែកខ្ញែក ដែលនាំឱ្យប្រសិទ្ធផលមិនទាន់ឈានដល់កម្រិតកំពូល ព្រមជាមួយនឹងការគ្របដណ្តប់ឈោងចាប់ទៅលើតំបន់ភូមិសាស្ត្រនានា នៅមានភាពអន់ខ្សោយ ហើយការផ្តល់តម្លៃលក់រាយទៅឱ្យផលិតករ នៅមានកម្រិតទាប។ កត្តារាំងស្ទះចម្បងៗរួមមាន ផលិតកម្មមានកម្រិតទាប និងមានគុណភាពទាប ហេដ្ឋារចនាសម្ព័ន្ធក្រោយពេលប្រមូលផល មានកម្រិត និងគុណភាពទាប ថ្លៃចំណាយថាមពលមានកម្រិតខ្ពស់ ការទទួលបានទីផ្សារ និងសេវាគាំទ្រធាតុចូល និងធាតុចេញកសិពាណិជ្ជកម្មមិនគ្រប់គ្រាន់ និង ការកើនឡើងនូវភាពងាយរងគ្រោះនៃខ្សែសង្វាក់តម្លៃកសិធុរកិច្ច ចំពោះផលប៉ះពាល់ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ។ |

| | |
|---|---|
| | គម្រោងនេះ នឹងដោះស្រាយកត្តារាំងស្ទះខាងលើ តាមរយៈ (១) ការស្តារ និងការកែលម្អទៅលើភាពធន់ទៅនឹងអាកាសធាតុ ចំពោះផលិតកម្មសំខាន់ៗ និង/ឬ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការចែកចាយ (២) ការបង្កើនការប្រើប្រាស់ជីវថាមពលដើម្បីកាត់បន្ថយថ្លៃចំណាយធាតុចូលថាមពល និងជី និង (៣) ការបង្កើតឱ្យមាននូវបរិយាកាសអំណោយផលមួយ សម្រាប់កសិពាណិជ្ជកម្ម តាមរយៈគោលនយោបាយមានគោលដៅ កិច្ចគាំទ្របច្ចេកទេស និងព័ត៌មានទីផ្សារ។ គម្រោងនេះ មានគោលបំណងអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ សម្រាប់កសិផលដុល ដូចជា ស្រូវ និង កសិផលសាច់ប្រាក់ ដូចជា ម្រេចនៅក្នុងប្រទេសកម្ពុជា។ តំបន់គម្រោងនឹងត្រូវបានជ្រើសរើសក្នុងលក្ខណៈមួយ ដែលបំពេញបន្ថែមដល់ការវិនិយោគរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងធារាសាស្រ្ត តាមបណ្តោយរបៀងសេដ្ឋកិច្ចរបស់មហាអនុតំបន់ទន្លេមេគង្គ។ តាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ កិច្ចគាំទ្រកសិពាណិជ្ជកម្ម មានគោលដៅ និង កសាងសមត្ថភាព គម្រោងនេះ ហើយនឹងលើកកម្ពស់ពិពិធកម្មកសិផល និងផលិតភាពកសិកម្ម ធ្វើពិពិធកម្មទៅលើជម្រើសជីវភាពរស់នៅ ដែលជាហេតុនាំឱ្យគម្រោងនេះ អាចជួយដល់កសិករខ្នាតតូចឱ្យផ្លាស់ប្តូរពីកសិកម្មយថាផល ទៅជាកសិកម្មបែបពាណិជ្ជកម្មនៅក្នុងតំបន់គម្រោង។ គម្រោងនេះ នឹងកំណត់រកកាលានុវត្តភាពសម្រាប់វិស័យឯកជន ព្រមទាំងនឹងជួយជម្រុញឱ្យមានភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន (PPPs) ជាពិសេសនៅក្នុងទីផ្សារ និងការធ្វើទីផ្សារធាតុចូល និងធាតុចេញកសិពាណិជ្ជកម្ម។ គម្រោងនេះ ក៏នឹងលើកកម្ពស់ការធ្វើពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ចកាន់តែ ជ្រាលជ្រៅនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ តាមរយៈសុខដុមនីយកម្មទៅលើបទដ្ឋាន សម្រាប់ការផ្តល់ចំណីអាហារកសិកម្មដែលមានសុវត្ថិភាព និង ប្រកបដោយគុណតម្លៃបន្ថែម។ |
| ផលប៉ះពាល់ | ផលិតភាព គុណភាព និងការបន្ថែមគុណតម្លៃផលិតផលកសិកម្ម ព្រមទាំងប្រាក់ចំណូលគ្រួសារជនបទនៅក្នុងតំបន់គម្រោង មានការកើនឡើងនៅឆ្នាំ២០២៧។ |
| លទ្ធផល | ខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្មដែលមិនបង្កផលប៉ះពាល់ដល់អាកាសធាតុក្នុង ប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ា ត្រូវបានអភិវឌ្ឍន៍។ |

| | |
|---|---|
| ទិន្នផល | ១. ហេដ្ឋារចនាសម្ព័ន្ធខ្សែសង្វាក់តម្លៃកសិពាណិជ្ជកម្មសំខាន់ៗ ត្រូវបានកែលម្អ។<br>២. ការប្រើប្រាស់ជីវថាមពល និងការគ្រប់គ្រងជីវម៉ាស់ប្រកបដោយនិរន្តរភាពត្រូវបានពង្រីក។<br>៣. គោលនយោបាយស្តីពីកសិពាណិជ្ជកម្ម និងសេវាគាំទ្រសមត្ថភាពត្រូវបានពង្រឹង។ |
| ទីតាំងភូមិសាស្ត្រ | |

| ប្រភេទគោលនយោបាយស្តីពីកិច្ចការពារបរិស្ថាន និងសង្គម | |
|---|---|
| **បរិស្ថាន** | B |
| **ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត** | B |
| **ជនជាតិដើមភាគតិច** | B |

| សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម |
|---|
| ទិដ្ឋភាពផ្នែកបរិស្ថាន |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត |
| ជនជាតិដើមភាគតិច |

| ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ |
|---|
| ក្នុងអំឡុងពេលនៃការរៀបចំគម្រោង |
| ក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង |

| | |
|---|---|
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Ancha Srinivasan |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ (SERD) |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកបរិស្ថាន, ធនធានធម្មជាតិ និង កសិកម្ម, SERD |
| ទីភ្នាក់ងារប្រតិបត្តិ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - អសយដ្ឋានអគារលេខ៤០ វិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា |

| កាលវិភាគ | |
|---|---|
| **ការអនុម័តលើទស្សនទាន** | - |
| **បេសកកម្មស្វែងរកការពិត** | ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ |
| **កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង** | - |
| **ការអនុម័ត** | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាពទិន្នន័យគម្រោងចុងក្រោយ | ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ីព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការបង្កប់អត្ថន័យឡើយ រាប់បញ្ចូលការពុំមានកំណត់ទៅលើការធានាចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់មួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ីមិនផ្តល់ការធានាណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។